ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥០០ សហវ.

MINISTRY OF PUBLIC WORKS AND TRANSPORT

ក្រសួងសាធារណការ និងដឹកជញ្ជូន

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការកែសម្រួលគណៈកម្មាធិការសម្រាប់គ្រប់គ្រងកិច្ចព្រមព្រៀងសម្បទានគម្រោង ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងសាធារណការ និងដឹកជញ្ជូន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការដំឡើងនាយកដ្ឋានសំណង់ប្រព័ន្ធចម្រោះទឹកកខ្វក់ ទៅជាអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ ស្ដីពីការប្រែក្លាយ និងដំឡើងវិទ្យាស្ថានជាតិបណ្ដុះបណ្ដាលបច្ចេកទេសសាធារណការ និងដឹកជញ្ជូន ទៅជាវិទ្យាស្ថានតេជោសែនសាធារណការ និងដឹកជញ្ជូន របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ ស្ដីពីការដំឡើងនាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ ទៅជាអគ្គនាយកដ្ឋានបច្ចេកវិទ្យា និងទំនាក់ទំនងសាធារណៈ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញប្រកាសអន្តរក្រសួងលេខ ៨២៥ សហវ.ប្រក ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២២ ស្ដីពីការបង្កើតគណៈកម្មាធិការសម្រាប់គ្រប់គ្រងកិច្ចព្រមព្រៀងសម្បទានគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន

**សម្រេច**

**ប្រការ១.-**

ត្រូវបានកែសម្រួលគណៈកម្មាធិការសម្រាប់គ្រប់គ្រងកិច្ចព្រមព្រៀងសម្បទានគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ ហៅកាត់ថា "**គ.ក.ផ.**" រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "កសហវ" និងក្រសួងសាធារណការ និងដឹកជញ្ជូន "កសដ" ដែលមានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តម **មាស សុខសេនសាន** | រដ្ឋលេខាធិការ កសហវ | សហប្រធាន |
| ២. ឯកឧត្តម **ស្វួន ហេង** | រដ្ឋលេខាធិការ កសដ | សហប្រធាន |
| ៣. ឯកឧត្តម **ស៊ឹម ធីរៈ** | អនុរដ្ឋលេខាធិការ កសហវ | អនុប្រធាន |
| ៤. ឯកឧត្តម **ស៊ីង សុគង់** | អនុរដ្ឋលេខាធិការ កសដ | អនុប្រធានប្រចាំការ |
| ៥. ឯកឧត្តម **ឌិម ម៉ាក់ធារិទ្ធ** | អគ្គនាយក នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន កសហវ | អនុប្រធាន |
| ៦. ឯកឧត្តម **ហេង រត្នពិសិដ្ឋ** | អគ្គនាយក នៃអគ្គនាយកដ្ឋានសាធារណការ កសដ | អនុប្រធាន |
| ៧. ឯកឧត្តម **នេត មុន្នី** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ កសហវ | សមាជិក |
| ៨. ឯកឧត្តម **ហ៊ាង ឧត្តរា** | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស កសដ | សមាជិក |
| ៩. ឯកឧត្តម **កែន រដ្ឋា** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ កសដ | សមាជិក |

| | | |
|---|---|---|
| ១០. ឯកឧត្តម **ឈួន ម៉ន់** | អគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក កសដ | សមាជិក |
| ១១. ឯកឧត្តម **ម៉ៅ សុទ្ធាឃុត្តិ** | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យា និងទំនាក់ទំនងសាធារណៈ កសដ | សមាជិក |
| ១២. លោក **ឡុង ជីវីណា** | ប្រធាននាយកដ្ឋានផ្លូវល្បឿនលឿន ស្ពានធំៗ និងវិនិយោគ កសដ | សមាជិក |

**ប្រការ២ .-**

**គ.គ.ផ.** មានភារកិច្ច ដូចខាងក្រោម÷

- ដឹកនាំ ត្រួតពិនិត្យ ការអនុវត្តរួមនៃគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ សំដៅធានាអនុលោមភាព និងការបំពេញកាតព្វកិច្ចរបស់គូភាគីក្រោមកិច្ចព្រមព្រៀងសម្បទាន
- សម្រេច និងអនុម័តលើការងារពាក់ព័ន្ធនឹងការគ្រប់គ្រងកិច្ចព្រមព្រៀងសម្បទាន គម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ លើកលែងតែកិច្ចការទាក់ទងនឹងកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ ដែលស្ថិតក្រោមដែនសមត្ថកិច្ច និងទាមទារការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងករណីមានវេទយិតភាព ត្រូវស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល
- ជំរុញ និងសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀតរបស់រាជរដ្ឋាភិបាល និងក្រុមហ៊ុនសម្បទានិក ដើម្បីដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធការអនុវត្តកិច្ចព្រមព្រៀងសម្បទាន ព្រមទាំងផ្តល់អនុសាសន៍ណែនាំគ្រប់ភាគីពាក់ព័ន្ធ ដើម្បីបំពេញកាតព្វកិច្ច ដូចមានចែងក្នុងកិច្ចព្រមព្រៀងសម្បទាន
- គ្រប់គ្រងសំណើកែសម្រួលក្នុងកិច្ចព្រមព្រៀងសម្បទានគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ, ការបែងចែកហានិភ័យ, ការដោះស្រាយសំណង/វិវាទ, និងដំណោះស្រាយផ្សេងៗទៀត រួមទាំងការរំលាយកិច្ចសន្យា។ ក្នុងករណីសំណើកែសម្រួលទាំងនោះមានផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ត្រូវលើកសំណើទាំងនោះជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច
- ពិនិត្យ និងអនុម័តលើរបាយការណ៍វឌ្ឍនភាព របាយការណ៍ប្រចាំត្រីមាស និងរបាយការណ៍ពាក់ព័ន្ធផ្សេងៗទៀត
- បំពេញមុខងារផ្សេងទៀត តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ៣ .-**

**គ.គ.ផ.** មានអង្គភាពគ្រប់គ្រងគម្រោង ជាលេខាធិការដ្ឋាន។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពគ្រប់គ្រងគម្រោង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ៤ .-**

អនុប្រធាន និងសមាជិកនៃ **គ.គ.ផ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់សហប្រធាន។ ក្នុងករណី

ចាំបាច់, **គ.ក.ផ.** អាចអញ្ជើញមន្ត្រីជំនាញពាក់ព័ន្ធផ្សេងទៀតពី កសហវ និង កសដ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ទីប្រឹក្សា និងជំនាញការផ្សេងៗ ឱ្យចូលរួមប្រជុំ តាមតម្រូវការចាំបាច់។

ក្នុងករណីសហប្រធានអវត្តមាន អនុប្រធានមានសិទ្ធិពេញលេញ ដើម្បីដឹកនាំកិច្ចប្រជុំតាមការប្រគល់សិទ្ធិរបស់សហប្រធាន។

**គ.ក.ផ.** មានសិទ្ធិបង្កើតអនុគណៈកម្មការចំពោះកិច្ច ក្នុងករណីចាំបាច់ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ជាដំណោះស្រាយចំពោះបញ្ហាជាក់លាក់ណាមួយ។

**ប្រការ៥ .-**

លេខាធិការដ្ឋានប្រើប្រាស់ថវិការដ្ឋ ឬប្រភពហិរញ្ញប្បទានស្របច្បាប់ផ្សេងៗទៀត សម្រាប់ទ្រទ្រង់កិច្ចដំណើរការរបស់ខ្លួន និង **គ.ក.ផ.** តាមការចាំបាច់ ដោយលើកសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងសម្រេចតាមនីតិវិធីជាធរមាន។

**ប្រការ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អាទិត្យ ២ រោច ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ១២ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងសាធារណការ និងដឹកជញ្ជូន**

ប៉េង ពោធិ៍នា

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ